# ដឹងអំពីសិទ្ធបោះឆ្នោតរបស់អ្នក



KEEP 20
GOING 20

SEAD

# សិទ្ធអ្នកបោះឆ្នោតទូទៅ

1. ប្រសិនបើស្ថានីយ៍បោះឆ្នោតបិទក្នុងអំឡុងពេលដែលអ្នកនៅក្នុងជួរ សូមបន្តការតម្រង់ជួររបស់អ្នក។ អ្នកមានសិទ្ធបោះឆ្នោត។

2. ប្រសិនបើអ្នកបំពេញសន្លឹកឆ្នោតរបស់អ្នកខុស សូមស្នើសុំសន្លឹកថ្មី។

3. ប្រសិនបើម៉ាស៊ីនបោះឆ្នោតខូចនៅស្ថានីយ៍របស់អ្នក សូមស្នើរកសន្លឹកឆ្នោតជាក្រដាស។

ប្រសិនបើអ្នកជួបបញ្ហាណាមួយ ឬ
មានសំណួរនៅថ្ងៃបោះឆ្នោត
សូមទូរស័ព្ទមកកាន់លេខគាំពារអ្នកបោះឆ្នោត៖

**អង់គ្លេស៖ :**
1-866-OUR-VOTE / 1-866-687-8683

**សម្រាប់ភាសាបេងហ្គាលី កាតាំង ហុីនឌី អ៊ីឌូ កូរ៉េ កុកងឺ តាហ្គាឡុក ឬ វៀតណាម៖**
1-888-274-8683

“ខ្ញុំកំពុងស្ថិតនៅស្ថានីយ៍បោះឆ្នោត
ហើយបុគ្គលិកស្ថានីយ៍បាននិយាយថាឈ្មោះខ្ញុំអត់មាននៅក្នុងបញ្ជីអ្នកចុះឈ្មោះបោះឆ្នោតទេ។”

## សិទ្ធរបស់អ្នក

ត្រឹមឆ្នាំ២០២០ មានរដ្ឋសរុបចំនួន២១
ដែលអនុញ្ញាតឲ្យពលរដ្ឋរបស់ខ្លួន
ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការបោះឆ្នោត
អាចចុះឈ្មោះ និង បោះឆ្នោតបាននាថ្ងៃបោះឆ្នោត។

អ្នកបោះឆ្នោតមានសិទ្ធទទួលបាននូវសន្លឹកឆ្នោតបណ្តោះអាសន្ន
ដែលជាសន្លឹកឆ្នោតមួយប្រភេទផ្សេងទៀត
ដែលធានាថានឹងមិនមានអ្នកបោះឆ្នោតណាម្នាក់ត្រូវការគេដកចេញពីដំណើរការបោះឆ្នោត
ដោយសារកំហុសរដ្ឋបាលឡើយ។
នេះគឺជាវិធានការសុវត្ថិភាពមួយសម្រាប់អ្នកបោះឆ្នោតដែលមានលក្ខណៈសម្បត្តិបោះឆ្នោតមិនទាន់ជាក់លាក់
ឬ ដែលអាចបញ្ជាក់បាននាពេលក្រោយ។

ក្រោយថ្ងៃបោះឆ្នោត មន្ត្រីរៀបចំការបោះឆ្នោត
ត្រូវធ្វើការស៊ើបអង្កេតមើលថាតើអ្នកមានសិទ្ធបោះឆ្នោត
និង បានចុះឈ្មោះដែរឬទេ។ ប្រសិនបើអ្នកមានសិទ្ធគ្រប់គ្រាន់
និងបានចុះឈ្មោះមែន ពួកគេនឹងរាប់សន្លឹកឆ្នោតរបស់អ្នកដែរ។

## តើត្រូវធ្វើយ៉ាងណា

សូមស្នើឲ្យមន្ត្រីបោះឆ្នោតឆែករកឈ្មោះរបស់អ្នកក្នុងបញ្ជីអ្នកចុះឈ្មោះបោះឆ្នោតជាថ្មីម្តងទៀត។
សូមប្រកបតួអក្សរសម្រាប់ឈ្មោះបញ្ជីជាតិរបស់អ្នក ជូនដល់មន្ត្រីបោះឆ្នោត
ឬក៏បង្ហាញអត្តសញ្ញាណប័ណ្ណណាមួយដែលមានឈ្មោះអ្នកនៅលើនោះ។

ប្រសិនបើមន្ត្រីបោះឆ្នោតនៅតែមិនអាចរកឈ្មោះអ្នកឃើញ
សូមបញ្ជាក់ថាតើអ្នកកំពុងស្ថិតនៅស្ថានីយ៍បោះឆ្នោតត្រឹមត្រូវដែរឬ ទេ៖
សូមស្នើឲ្យមន្ត្រីបោះឆ្នោតឆែកក្នុងប្រព័ន្ធចុះឈ្មោះទូទាំងរដ្ឋ ក្រែងលោថា
អ្នកត្រូវគេចុះឈ្មោះនៅស្ថានីយ៍មួយផ្សេងទៀត ឬក៏ទូរស័ព្ទមកកាន់លេខ
1-866-OUR-VOTE ហើយសួររកជំនួយដើម្បីបញ្ជាក់រកស្ថានីយ៍បោះឆ្នោតត្រឹមត្រូវរបស់អ្នក។

បើមន្ត្រីបោះឆ្នោតនៅតែមិនអាចរកឈ្មោះអ្នកឃើញ ឬ
ប្រសិនបើអ្នកមិនអាចធ្វើដំណើរទៅកាន់ស្ថានីយ៍ត្រឹមត្រូវនោះបាន
សូមស្នើរកសន្លឹកឆ្នោតបណ្តោះអាសន្ន។*

## ធនធាននានា

ប្រសិនបើអ្នកត្រូវបានគេរុញចេញ ឬ ត្រូវបានគេបដិសេដមិនឲ្យសន្លឹកឆ្នោតបណ្តោះអាសន្ន
សូមទូរស័ព្ទមកកាន់លេខគាំពារអ្នកបោះឆ្នោតនៅលេខ 1-866-OUR-VOTE

*ច្បាប់អំពីការប្រើប្រាស់សន្លឹកឆ្នោតបណ្តោះអាសន្ន មានភាពខុសគ្នាពីរដ្ឋមួយទៅរដ្ឋមួយ។ រដ្ឋមួយចំនួនដូចជា អាយដាហូ មីនេសូតា
និង ញូហែមស៊ី មិនប្រើប្រាស់សន្លឹកឆ្នោតបណ្តោះអាសន្នទេ។ លោកអ្នកអាចឆែកច្បាប់រដ្ឋរបស់លោកអ្នកទាក់ទងនឹងរឿងនេះបានទៅទីនេះ។

# “ខ្ញុំមានពិការភាព។”

## សិទ្ធរបស់អ្នក

យោងតាមច្បាប់សហព័ន្ធ រាល់ស្ថានីយ៍បោះឆ្នោតថ្នាក់សហព័ន្ធទាំងអស់ ត្រូវបំពាក់នូវបរិក្ខារ និង សេវាកម្មជំនួយសម្រាប់អ្នកបោះឆ្នោតដែលជាជនចាស់ជរា និង ពិការ។ ការអនុញ្ញាតិឲ្យមានការបោះឆ្នោតអែបចិញ្ចើមផ្លូវ មិនទាន់បំពេញបាននូវលក្ខខ័ណ្ឌរបស់ច្បាប់គាំពារជនជាតិអាមេរិកាំងដែលមានពិការភាពទេ។

នៅក្នុងការបោះឆ្នោតថ្នាក់សហព័ន្ធ រាល់ស្ថានីយ៍បោះឆ្នោតត្រូវមានបំពាក់នូវប្រព័ន្ធបោះឆ្នោតយ៉ាងតិចមួយ ដែលអនុញ្ញាតិឲ្យអ្នកបោះឆ្នោតដែលមានពិការភាព អាចបោះឆ្នោតដោយសម្ងាត់និងឯករាជ្យបាន។ ជាធម្មតា នេះគឺជាម៉ាស៊ីនដែលអាចអានសន្លឹកឆ្នោត និង អាចឲ្យអ្នកបោះឆ្នោតដោយចុចប៊ូតុងបាន។

យោងតាមច្បាប់សហព័ន្ធ អ្នកបោះឆ្នោតដែលមានពិការភាព និង អ្នកបោះឆ្នោតដែលមានការលំបាកក្នុងការអាន និង សរសេរភាសាអង់គ្លេស មានសិទ្ធទទួលបាននូវជំនួយផ្ទាល់ខ្លួននៅស្ថានីយ៍បោះឆ្នោតពីមនុស្សណាមួយដែលគេពេញចិត្ត។ ជំនួយការរូបនេះ មិនអាចជានិយោជក តំណាងរបស់និយោជក ឬជា ភ្នាក់ងារ ឬ មន្រ្តីនៅក្នុងសហជីពការងាររបស់អ្នកបោះឆ្នោតឡើយ។ ជំនួយការរូបនេះ ចាំបាច់ត្រូវគោរពដល់ភាពឯកជនរបស់អ្នកបោះឆ្នោត ដោយមិនត្រូវលួចមើលសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតឡើយ លើកលែងតែមានការស្នើសុំពីអ្នកបោះឆ្នោតឲ្យធ្វើដូច្នេះ។

មន្រ្តីបោះឆ្នោតត្រូវរៀបចំការសម្រួលដែលសមហេតុផល តាមចាំបាច់ ដើម្បីជួយឲ្យអ្នកបោះឆ្នោតបាន។

អ្នកបោះឆ្នោតដែលមានពិការភាពផ្នែកសតិបញ្ញា មិនអាចត្រូវបានគេរុញចេញពីមណ្ឌលបោះឆ្នោត ដោយសារមន្រ្តីបោះឆ្នោតគិតថាគាត់មិនមាន “លក្ខណៈសម្បត្តិ” គ្រប់គ្រាន់ដើម្បីបោះឆ្នោតឡើយ។

## តើត្រូវធ្វើយ៉ាងណា

អ្នកអាចនាំសមាជិកគ្រួសារ មិត្តភក្តិ ឬ មនុស្សណាម្នាក់ដែលអ្នកពេញចិត្ត មកជួយអ្នកបាននៅស្ថានីយ៍បោះឆ្នោត។

ប្រសិនបើអ្នកនាំមនុស្សមកជួយ សូមមេត្តាប្រាប់ឲ្យមន្រ្តីស្ថានីយ៍បោះឆ្នោតបានដឹងផង នៅពេលអ្នកទៅបញ្ជាក់វត្តមាន។ មន្រ្តីស្ថានីយ៍ អាចនឹងសុំឲ្យអ្នកស្បថថាអ្នកពិតជាមានពិការភាព និង បានស្នើសុំបុគ្គលរូបនោះឲ្យមកជួយអ្នកមែន។ ជំនួយការរបស់អ្នករូបនេះ អាចនឹងត្រូវបានគេសុំឲ្យបំពេញបែបបទស្បថថា រូបគាត់មិនបានបង្គាប់រូបអ្នកឲ្យបោះឆ្នោតតាមបែបណាមួយឡើយ។

ប្រសិនបើមានការតម្រង់ជួរវែង ហើយអ្នកមានបញ្ហាសុខភាពផ្លូវកាយ ឬ ផ្លូវចិត្ត ឬ ពិការភាព ដែលបង្កការលំបាកដល់ការតម្រង់ជួររបស់អ្នក សូមប្រាប់ដល់មន្រ្តីស្ថានីយ៍ដើម្បីស្វែងរកជំនួយ។

ប្រាប់មន្រ្តីបោះឆ្នោតអំពីអ្វីដែលអ្នកត្រូវការ។

ប្រសិនបើអ្នកមិនអាចចូលក្នុងស្ថានីយ៍បោះឆ្នោតបាន ដោយសារមានបញ្ហាផ្លូវដើរ សូមស្នើសុំជំនួយអែបចិញ្ចើមផ្លូវពីមន្រ្តីស្ថានីយ៍។

ប្រសិនបើអ្នកមានការពិបាកក្នុងការប្រើប្រាស់សម្ភារៈដែលគេផ្តល់ជូន សម្រាប់ការជ្រើសរើស ត្រួតពិនិត្យ ឬ គូសសន្លឹកឆ្នោតរបស់អ្នក សូមប្រាប់មន្រ្តីស្ថានីយ៍ឲ្យបានដឹង ហើយស្នើសុំរកជំនួយតាមការគួរ។ ច្បាប់បានតម្រូវឲ្យមានការសម្រួលដល់រាល់ជនចាស់ជរា និង ពិការ។

ប្រសិនបើអ្នកជួបនូវឧបសគ្គណាមួយក្នុងការបោះឆ្នោតដោយសម្ងាត់ និង ឯករាជ្យ ឬ មិនអាចគូសសន្លឹកឆ្នោតរបស់អ្នកបាន សូមរាយការបញ្ហានេះមកកាន់លេខគាំពារអ្នកបោះឆ្នោត តាមរយៈលេខ 1-866-OUR-VOTE។

## ធនធាននានា

ស្វែងរកបទណែនាំលម្អិតអំពីការបោះឆ្នោតនៅ Bazelon Center for Mental Health Law.

សម្រាប់ជំនួយទាក់ទងនឹងការបោះឆ្នោតសម្រាប់អ្នកពិការ សូមអានគេហទំព័រ Autistic Self Advocacy Network.

អានព័ត៌មាននៅគេហទំព័រ SABE’s GoVoter Project ដើម្បីទទួលបាននូវការហ្វឹកហ្វឺនអំពីការប្រើប្រាស់សិទ្ធរបស់អ្នក ក្នុងនាមជាអ្នកបោះឆ្នោតដែលមានពិការភាព។

សម្រាប់ព័ត៌មានទាក់ទងនឹងការបោះឆ្នោតជាភាសាសញ្ញាបែបអាមេរិកាំង សូមបើកគេហទំព័រ SignVote.

# “ខ្ញុំនិយាយភាសាអង់គ្លេសមិនសូវបានល្អ។”

## សិទ្ធរបស់អ្នក

យោងតាមច្បាប់សហព័ន្ធ អ្នកបោះឆ្នោតទាំងឡាយណា
ដែលមានការលំបាកក្នុងការអាន ឬសរសេរភាសាអង់គ្លេស
អាចទទួលបាននូវជំនួយផ្ទាល់ខ្លួនពីមនុស្សណាម្នាក់ដែលគេពេញចិត្ត
ដរាបណាបុគ្គលរូបនោះមិនមែនជានិយោជក តំណាងរបស់និយោជក
ឬជាភ្នាក់ងារ ឬ មន្ត្រីរបស់សហជីពការងាររបស់អ្នកបោះឆ្នោត។

រាល់ខេត្តដែលមានចែងនៅក្នុងផ្នែក២០៣ នៃច្បាប់ទាក់ទងនឹងសិទ្ធបោះឆ្នោត
ចាំបាច់ត្រូវមានផ្តល់ជូនដល់អ្នកបោះឆ្នោតនូវជំនួយពហុភាសា
នៅក្នុងភាសាជាក់លាក់មួយចំនួន។ នេះមានន័យថា ខេត្តទាំងនោះ
ត្រូវមានបុគ្គលិកបោះឆ្នោតដែលចេះនិយាយភាសាហើយមានបកប្រែឯកសារ
និង ព័ត៌មានទាក់ទងនឹងការបោះឆ្នោតជាភាសាទាំងនោះដូចគ្នា។
សូមឆែកមើលថាតើខេត្តរបស់អ្នក
ត្រូវបានច្បាប់តម្រូវឲ្យមានផ្តល់ជូននូវសេវាភាសាសម្រាប់ការបោះឆ្នោត
ក្នុងភាសាដែលអ្នកនិយាយដែរឬទេ។

## តើត្រូវធ្វើយ៉ាងណា

អ្នកអាចនាំសមាជិកគ្រួសារ មិត្តភក្តិ ឬ
មនុស្សណាម្នាក់ដែលអ្នកពេញចិត្តមកជួយអ្នកបាននៅស្ថានីយ៍បោះឆ្នោត។
សូមកុំនាំនិយោជក ឬ តំណាងរបស់និយោជក ឬ សហជីពការងាររបស់អ្នកឲ្យសោះ។

ប្រសិនបើអ្នករស់នៅក្នុងខេត្តដែលត្រូវបានច្បាប់តម្រូវឲ្យមានជំនួយពហុភាសាសម្រាប់ភាសារបស់អ្នក
អ្នកអាចស្នើសុំជំនួយផ្ទាល់មាត់ពីមន្ត្រីបោះឆ្នោតពហុភាសា
ហើយស្នើរកឯកសារបោះឆ្នោត ដូចជាសន្លឹកឆ្នោត ជាភាសារបស់អ្នកបាន។

ប្រសិនបើអ្នកមានបញ្ហាបោះឆ្នោតដោយសារកង្វះជំនាញភាសាអង់គ្លេស សូមទាក់ទងមកកាន់លេខដូចខាងក្រោម៖

**អង់គ្លេស**
1-866-OUR-VOTE / 1-866-687-8683
**ភាសាបេងហ្គាលី ចិនកាតាំង ហ៊ីនឌី អ៊ីឌូ កូរ៉េ ចិនកុកងឺ តាហ្គាឡុក ឬ វៀតណាម៖**
1-888-API-VOTE / 1-888-274-8683

## ធនធាននានា

សម្រាប់បទណែនាំលម្អិតអំពីជំនួយបោះឆ្នោតពហុភាសា សូមបើក Asian Americans Advancing Justice.

# “មានមនុស្សម្នាក់កំពុងព្យាយាមរារាំងសិទ្ធបោះឆ្នោតរបស់ខ្ញុំ។”

## ឧទាហរណ៍ទាក់ទងនឹងការគំរាមកំហែងអ្នកបោះឆ្នោត

ការសាកសួរដេញដោលអ្នកបោះឆ្នោតអំពីរឿងសញ្ជាតិ
ប្រវត្តិបទឧក្រិដ្ឋ ឬ លក្ខណៈសម្បត្តិដើម្បីបោះឆ្នោតផ្សេងទៀត
ដោយប្រើកិរិយាមិនសមរម្យ។

ការតាំងខ្លួនបន្លំជាមន្ត្រីបោះឆ្នោត។

ដាក់បង្ហាញនូវផ្លាកឃោសនាក្លែងក្លាយ ឬ
ខុសពីការពិតអំពីការបន្លំសន្លឹកឆ្នោត និង
ការដាក់ទោសព្រហ្មទណ្ឌដែលពាក់ព័ន្ធ។

ការរំខានអុកឡុកក្នុងទម្រង់ផ្សេងទៀត
ជាពិសេសការរំខានចំពោះអ្នកដែលមិនចេះភាសាអង់គ្លេស
និង អ្នកបោះឆ្នោតស្បែកពណ៌។

ផ្សព្វផ្សាយព័ត៌មានក្លែងបន្លំអំពីល័ក្ខខ័ណ្ឌសម្រាប់អ្នកបោះឆ្នោត។

- ទោះក្នុងរដ្ឋណាក៏ដោយ អ្នកមិនចាំបាច់ចេះភាសាអង់គ្លេស ទើបបោះឆ្នោតបានទេ។
- ទោះក្នុងរដ្ឋណាក៏ដោយ អ្នកមិនចាំបាច់ត្រូវឆ្លងកាត់ការធ្វើតេស្ត ទើបបោះឆ្នោតបានទេ។
- រដ្ឋខ្លះ មិនមានតម្រូវឲ្យអ្នកបោះឆ្នោតបង្ហាញអត្តសញ្ញាណប័ណ្ណមានរូបថតទេ។

## សិទ្ធរបស់អ្នក

ការគំរាមកំហែងអ្នកបោះឆ្នោត គឺជាអំពើខុសច្បាប់។ “ការគំរាមកំហែង ឬ បង្ខំ... បុគ្គលណាមួយ
ក្នុងគោលបំណងជ្រៀតជ្រែក សិទ្ធរបស់បុគ្គលនោះក្នុងការបោះឆ្នោតតាមចិត្តចង់របស់គាត់”
ជាបទល្មើសកម្រិតសហព័ន្ធ។

## ធនធាននានា

នៅក្នុងរដ្ឋជាច្រើន អ្នកអាចផ្តល់នូវពាក្យសម្បថទៅកាន់មន្ត្រីបោះឆ្នោត
ដើម្បីបំពេញលក្ខណៈសម្បត្តិបោះឆ្នោតនៅក្នុងរដ្ឋរបស់អ្នក និង បន្តទៅគូសសន្លឹកឆ្នោតបាន។

សូមរាយការរាល់ការគំរាមកំហែងមកកាន់លេខគាំពារអ្នកបោះឆ្នោត តាមរយៈលេខ 1-866-OUR-VOTE។

# សេចក្ដីអំពាវនាវឲ្យធ្វើសកម្មភាព

សូមចែករំលែក និង ពន្យល់បង្ហាញសេចក្ដីណែនាំនៅក្នុងសៀវភៅនេះ
ជាមួយសហគមន៍ម៉ុង ខ្មែរ ឡាវ និង វៀតណាមរបស់អ្នក។

សូមចែករំលែករឿងរ៉ាវទាក់ទងនឹងការបោះឆ្នោតរបស់អ្នក ដោយផែកយើងខ្ញុំលើបណ្ដាញសង្គមតាមរយៈ
**Instagram @theseadproject + Twitter @plantthesead** និងប្រើហ៊ែស្ទែក
**#Elections2020.**

សូមចុះឈ្មោះដើម្បីទទួលបាននូវព្រឹត្តប័ត្ររបស់យើងនៅគេហទំព័រ
**theseadproject.org**

# KEEP 2020 GOING 2020

**theseadproject.org/keepgoing2020**

@theseadproject @plantthesead

@theseadproject

សូមថ្លែងអំណរគុណដល់សហជីពសេរីភាពស៊ីវិលអាមេរិកាំង និង អង្គការលើកស្ទួយយុត្តិធម៌អាស៊ីអាមេរិកាំង